ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

**អាជ្ញាធរប្រជារាស្ត្រខ្មែរ**

សំណុំរឿងព្រហ្មទណ្ឌ

**សាលាឧទ្ធរណ៍ ភ្នំពេញ**

លេខ ២០៤ / ២៨-០២-២០១៣

**សាលដីកា**

លេខ ៣៣ "ក្រ.V.ច" / ២៧-៦-២០១៤

បង្កើតតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នៅថ្ងៃទី ១២-៦-២០១៤ ដោយមានសមាសភាពដូចតទៅ:

សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

ក្រឡាបញ្ជី

លោក [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ២០៤ ចុះថ្ងៃទី ២៨-០២-២០១៣ ដោយមាន៖

**១-ជនជាប់ចោទ**

ក-ឈ្មោះ [redacted] សេរីវុធ ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិត ប្រាកដ ទីកន្លែងកំណើតនៅ [redacted] ទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" រៀនថ្នាក់ទី៨ (ប្តឹងឧទ្ធរណ៍) ។

-ប្រវត្តិនៃការផ្តន្ទាទោសនៃតុលាការធ្លាប់ជាប់ពន្ធនាគារព្រៃសចំនួន ៦ឆ្នាំ។

-ឃុំខ្លួនតាមដីកាបង្គាប់លេខ ១០៨៣ តព្រ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១២។

៣៧៦

**ខ-ឈ្មោះ** [redacted] **សុវណ្ណារ៉ា** ហៅ ខេម រ៉ា ភេទប្រុស អាយុ ២៨ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅ [redacted] ទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] "ស់" ម្ដាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] "រ" មានកូនចំនួន ០១នាក់ រៀនថ្នាក់ទី៦។ (ប៉្តឹងឧទ្ធរណ៍) ។

-ប្រវត្តិនៃការផ្ដន្ទាទោសនៃតុលាការធ្លាប់ជាប់ពន្ធនាគារព្រៃសចំនួន ៦ឆ្នាំ។

-ឃុំខ្លួនតាមដីកាបង្គាប់លេខ ១០៤២ តព្រ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១២។

-មានមេធាវីកាពារសិទ្ធិលោក [redacted] ចន្ថា ។

-ជាប់ចោទពីបទ: លួចមានស្ថានទម្ងន់ទោសដោយសារការប្រើអំពើហិង្សា និងបទកាន់កាប់ ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត្តិ ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ ៥៦Eo ផ្លូវលេខ២៣០ ក្រុមទី២២ ភូមិទី៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣,៣៥៧ និង មាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ។

**២-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ** [redacted] ភេទប្រុស អាយុ ៤៩ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះលេខ [redacted]

## **៦រឿងហេតុមានដូចតទៅ:**

កាលពីថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១១ វេលាម៉ោង ១២ និង ៤០នាទី ខណៈពេលដែល ជនរងគ្រោះឈ្មោះ [redacted] វត្ថែនរិន ភេទប្រុស អាយុ ៤៣ឆ្នាំ កំពុងអង្គុយលេងនៅខាងមុខផ្ទះ លេខ ៥៦Eo ផ្លូវលេខ២៣០ ក្រុមទី២២ ភូមិទី៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ រហូតដល់វេលាម៉ោង ១៣ និង១០នាទី ស្រាប់តែមានជនសង្ស័យពីរនាក់ជិះម៉ូតូមួយគ្រឿងម៉ាកស្កូបពីពណ៌សពីទិសខាងត្បូងមកឈប់មុខផ្ទះរបស់ជនរងគ្រោះ ហើយជនសង្ស័យដែលជិះខាងក្រោយក៏បានចុះមក រួចដកកាំភ្លើងខ្លីម៉ាក K៥៤ ភ្ជង់គំរាមជនរងគ្រោះឱ្យដោះខ្សែកប្លាកទីនចំនួនមួយខ្សែ បានសម្រេច រួចឡើងជិះម៉ូតូរត់គេចខ្លួនបាត់ទៅ។

លុះនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១២ ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ក៏បានធ្វើការឃាត់ខ្លួនជនរងសង្ស័យឈ្មោះ [redacted] សុវណ្ណារ៉ា ហៅ [redacted] រ៉ា ភេទប្រុស អាយុ ២៨ឆ្នាំ,ឈ្មោះ [redacted] វ៉ែយ៉ា ភេទប្រុស អាយុ ២៨ឆ្នាំ និងជនត្រូវចោទឈ្មោះ [redacted] សេរីវុធ ភេទប្រុស អាយុ ២៥ឆ្នាំ និងបានធ្វើការដកហូតកាំភ្លើងខ្លីចំនួន ០៣ដើម គឺម៉ាក K54 ចំនួន ០២ដើម និងកាំភ្លើងខ្លីម៉ាករ៉ូឡូ ពណ៌ស ចំនួន ០១ដើម។

បន្ទាប់មកនៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១២ វេលាម៉ោង ១៥ និង០០នាទី កម្លាំងសមត្ថកិច្ចនគរបាលប៉ុស្តិ៍បឹងសាឡាងក៏បានយករូបថតជនសង្ស័យចំនួន ០៣នាក់ ឱ្យជនរងគ្រោះឈ្មោះ [redacted] វត្ថែនរិន ហៅ រិន ពិនិត្យមើល ដែលលេខរៀងទី១ គឺជនសង្ស័យឈ្មោះ [redacted] វ៉ែយ៉ា ភេទប្រុស អាយុ ២៨ឆ្នាំ លេខរៀងទី២ឈ្មោះ [redacted] សេរីវុធ ភេទប្រុស អាយុ ២៥ឆ្នាំ និងលេខរៀងទី៣ ឈ្មោះ [redacted] សុវណ្ណារ៉ា ហៅ [redacted] រ៉ា ភេទប្រុស អាយុ ២៨ឆ្នាំ។ ពេលមើលរួចជនរងគ្រោះក៏បានចំណាំបានថា

ជនសង្ស័យដែលបានធ្វើសកម្មភាពប្លន់យកខ្សែក កាលទីថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១១ នៅមុខផ្ទះនោះគឺមានលេខរៀងទី២ ឈ្មោះ [redacted] សេរីវុធ ភេទ ប្រុស អាយុ ២៥ឆ្នាំ និងលេខរៀងទី៣ ឈ្មោះ [redacted] សុវណ្ណារ៉ា ហៅ [redacted] រ៉ា ភេទប្រុស អាយុ ២៨ឆ្នាំ។

**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ:០៤ "កប៥" ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ដូចតទៅ:

១-ផ្តន្ទាទោសៈ

ក-ជនជាប់ចោទឈ្មោះ [redacted] សេរីវុធ ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ

ខ-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារ៉ា ហៅ [redacted] រ៉ា ភេទប្រុស អាយុ ២៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗចំនួន ០៨ឆ្នាំ (ប្រាំបីឆ្នាំ) និងពិន័យក្នុងម្នាក់ៗចំនួន ៤.០០០.០០០ រៀល (បួនលានរៀល)។

ពីបទ: លួចមានស្ថានទម្ងន់ទោសដោយសារការប្រើអំពើហឹង្សា និងបទកាន់កាប់ ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត្តិ ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ ៥៦E០ ផ្លូវលេខ២៣០ ក្រុមទី២២ ភូមិទី៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣,៣៥៧ និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] សេរីវុធ និងឈ្មោះ [redacted] សុវណ្ណារ៉ា ហៅ ខេម រ៉ា រួមគ្នាសងសំណង និងជម្ងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ័ត្ននរិន ចំនួន ៤.០០០ ដុល្លា (បួនពាន់ដុល្លារ) សំណូមពរលើសពីនេះត្រូវបដិសេធចោល។

-សាលក្រមនេះជំនុំជម្រះជាសាធារណ:នៅថ្ងៃទី ០៩ ខែមករា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទមេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្តឹង និងប្រកាសជាសាធារណ: នៅថ្ងៃ១៧ ខែមករា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ កំបាំងមុខមេធាវីការពារជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**បាន**ឃើញពាក្យបណ្តឹងឧទ្ធរណ៍លេខ:១០៣ ចុះថ្ងៃទី ០៧-០២-២០១៣ របស់ជនជាប់-ចោទឈ្មោះ [redacted] សេរីវុធ និងបណ្តឹងឧទ្ធរណ៍លេខ: ១៣១ ចុះថ្ងៃទី ១៨-០២-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារ៉ា ប្តឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខ: ០៤ "កប៥" ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ គ្រប់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

**បាន**ឃើញរបាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។

**បាន**ឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

**នាពេលសវនាការ**

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ បានអានរបាយការណ៍សង្ខេបនៃរឿង**

-ជនជាប់ចោទឈ្មោះ [redacted] សេរីវុធ ថា: ថ្ងៃកើតហេតុប្រព្រឹត្តបទល្មើសខ្លួនមិនបានចូលរួមប្រព្រឹត្តទេ ប៉ូលីសចូលមកចាប់ពួកខ្លួននៅក្នុងផ្ទះសំណាក់ ហើយក៏នាំពួកខ្លួនទៅប៉ុស្តិ៍ឱ្យដើម-៤

បណ្ដឹងចង្អុលថាអ្នកណាប្រព្រឹត្តបទល្មើស ស្រាប់តែដើមបណ្ដឹងចង្អុលមកខ្លួនជាអ្នកប្រព្រឹត្តទៅវិញ អ្នកប្រព្រឹត្តបទល្មើស គឺឈ្មោះ [redacted] សុវណ្ណារ៉ា និងឈ្មោះ [redacted] វ៉ៃយ៉ា ជាអ្នកប្រព្រឹត្តបទល្មើសទេ នៅពេលប៉ូលីសចាប់ពួកខ្លួនទៅនោះ ដោយសារប៉ូលីសឆែកឆេរនៅបន្ទប់របស់គង់ សុវណ្ណារ៉ា មានកាំភ្លើង ៣ដើម ជារបស់ខ្លួន ០១ដើម ម៉ាកអាកា៥៤ ។ សំណូមពរសុំឱ្យរួចខ្លួនពីបទចោទប្រកាន់ ។

-ជនជាប់ចោទឈ្មោះ [redacted] **សុវណ្ណារ៉ា** ថា: ខ្លួនជាអ្នកប្រព្រឹត្តបទល្មើសនេះជាមួយឈ្មោះ [redacted] វ៉ៃយ៉ា នៅពេលប្រព្រឹត្តបទល្មើសឈ្មោះ [redacted] វ៉ៃយ៉ា ជាអ្នកបើកម៉ូតូ ខ្លួនជាអ្នកចុះទៅដកកាំភ្លើងម៉ាករ៉ូឡូក្លង់តំរាមយកខ្សែក ពេលពួកខ្លួនធ្វើសកម្មភាពសុទ្ធតែពាក់ម៉ាកមុខ និងពាក់មួកការពារ។ សំណូមពរសុំបន្ធូរបន្ថយទោស ។

-សាក្សីបំភ្លឺឈ្មោះ [redacted] **វ៉ៃយ៉ា** ថា: ខ្លួនមិនបានចូលរួមប្រព្រឹត្តបទល្មើសជាមួយឈ្មោះ [redacted] សុវណ្ណារ៉ា ទេ ព្រោះថ្ងៃនោះខ្លួននៅផ្ទះជាមួយបងស្រីខ្លួន គ្រាន់តែដឹងថា ឈ្មោះ [redacted] សុវណ្ណារ៉ា បានផ្ញើកាំភ្លើងម៉ាករ៉ូឡូនៅនឹងខ្លួន នៅពេលប៉ូលីសចាប់ពួកខ្លួនទៅប៉ុស្តិ៍ ជនរងគ្រោះមិនបានចង្អុលថាខ្លួនជាអ្នកប្រព្រឹត្តទេ ។ ខ្លួនជាប់ពន្ធនាគារចំនួន ០៣រឿង តែក្នុងរឿងនេះ ខ្លួនមិនជាប់ពាក់ព័ន្ធទេ ។

## តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋាន

ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារ៉ា បានសារភាពទទួលកំហុសដែលខ្លួនបានប្រព្រឹត្ត ដែលថាឈ្មោះ [redacted] វ៉ៃយ៉ា បានចូលរួមប្រព្រឹត្តជាមួយ ចំណែកជនជាប់ចោទឈ្មោះ [redacted] សេរីវុធ ថាមិនបានចូលរួមប្រព្រឹត្ត ការប្រព្រឹត្តបទល្មើសជនជាប់ចោទអះអាងថាមានការពាក់ម៉ាកមុខ និងពាក់មួកការពារ ភស្តុតាងសំអាងទៅលើជនរងគ្រោះចង្អុលទៅលើជនជាប់ចោទ សុំក្រុមប្រឹក្សាពិចារណាតាមច្បាប់ ។

## មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋាន

-កូនក្ដីខ្លួនឈ្មោះ [redacted] សេរីវុធ បានឆ្លើយបដិសេធថាមិនបានប្រព្រឹត្តបទល្មើសជាមួយឈ្មោះ [redacted] វណ្ណារ៉ា ទេ ចំណែកចម្លើយរបស់ [redacted] វណ្ណារ៉ា ក៏អះអាងថា ថ្ងៃប្រព្រឹត្តបទល្មើសខ្លួនមិនបានប្រព្រឹត្តជាមួយឈ្មោះ [redacted] សេរីវុធ ដែរ ប្រព្រឹត្តជាមួយឈ្មោះ [redacted] វ៉ៃយ៉ា ។ ការចោទប្រកាន់ មកលើកូនក្ដីខ្លួនគ្រាន់តែចង្អុលបង្ហាញពីដើមបណ្ដឹងថា កូនក្ដីខ្លួនជាអ្នកប្រព្រឹត្ត ។ ការប្រព្រឹត្តមាន ការពាក់មួក ពាក់ម៉ាក់ មិនអាចមើលឃើញទេ បទល្មើសមិនជាក់ស្ដែង ពុំមានភស្តុតាង សុំឱ្យរួចផុតពីបទចោទប្រកាន់ ។ ចំណែកឈ្មោះ [redacted] វណ្ណារ៉ា បានសារភាពកំហុសដែលខ្លួនបានប្រព្រឹត្តបទល្មើស សុំបន្ធូរបន្ថយទោស ។

## តុលាការជំនុំជម្រះ

ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ។

ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទឆ្លើយ និងសំណូមពរ ។

ក្រោយពីបានស្ដាប់តំណាងមហាអយ្យការធ្វើសន្និដ្ឋាន។

ក្រោយពីបានស្ដាប់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសន្និដ្ឋាន។

ក្រោយពីបានពិភាក្សាត្រឹមត្រូវហើយ។

## សាលាឧទ្ធរណ៍

### យល់ឃើញថាៈ

១-បណ្តឹងឧទ្ធរណ៍លេខ ១០៣ ចុះថ្ងៃទី ០៧.០២.២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] **សេរីឧុធ** ប្ដឹងនិងសាលក្រមព្រហ្មទណ្ឌលេខ ១៣១ ចុះថ្ងៃទី ១៨-០២-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] **ខណ្ណារ៉ា** ប្ដឹងនិងសាលក្រមព្រហ្មទណ្ឌលេខ ០៨ "កប៥" ចុះថ្ងៃទី ១៧.០១.២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ជនជាប់ចោទឈ្មោះ [redacted] **សុខណ្ណារ៉ា** បានសារភាពថាខ្លួនពិតជាបានធ្វើសកម្មភាពប្លន់យកទ្រព្យសម្បត្តិរបស់ជនរងគ្រោះមែន ធ្វើជាមួយឈ្មោះ [redacted] **រ៉ៃយ៉ា** មិនបានធ្វើសកម្មភាពជាមួយឈ្មោះ [redacted] សេរីឧុធ ទេ ។

៣-ជនជាប់ចោទឈ្មោះ [redacted] សេរីឧុធ បានឆ្លើយបដិសេធថានៅថ្ងៃ ២៤.១០.២០១១ នេះ ខ្លួនពុំបានប្រព្រឹត្តទេ ខ្លួនធ្លាប់ប្រព្រឹត្តតែម្តងទេ នៅក្នុងសំណុំរឿងមុនកាំភ្លើងដែលសមត្ថកិច្ចដកពីខ្លួន គឺជារបស់ឈ្មោះ [redacted] **ឡង់ម៉ាលីស** យកមកផ្ញើទុក ។

៤-តាមចម្លើយរបស់ឈ្មោះ [redacted] **រ៉ៃយ៉ា** ថាខ្លួនធ្លាប់ធ្វើសកម្មភាពប្លន់មែន តែមិនបានធ្វើជាមួយឈ្មោះ [redacted] **សុខណ្ណារ៉ា** ទេ សុំបដិសេធចម្លើយរបស់ឈ្មោះ [redacted] **សុខណ្ណារ៉ា** ។

៥-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ និងចង្អុលមុខក្រុមចោរដែលបានប្លន់ខ្សែករបស់ខ្លួនគឺចង្អុលចំមុខជនជាប់ចោទឈ្មោះ [redacted] **សេរីឧុធ** និងឈ្មោះ [redacted] **សុខណ្ណារ៉ា** ។ ដូចនេះទោះបីជនជាប់ចោទឈ្មោះ [redacted] **សេរីឧុធ** ឆ្លើយបដិសេធមិនទទួលស្គាល់យ៉ាងណាក៏ដោយ ក៏ពុំមានភស្តុតាងណាមកដោះបន្ទុកបានឡើយ ។ ចំណែកចម្លើយរបស់គង់ វណ្ណារ៉ា ឆ្លើយដាក់ឈ្មោះ [redacted] រ៉ៃយ៉ា ហើយ [redacted] រ៉ៃយ៉ា បដិសេធទៀត ភស្តុតាងដាក់បន្ទុកក៏គ្មាន សាលាដំបូងក៏ពុំបានធ្វើការចោទប្រកាន់ និងផ្តន្ទាទោសជនជាប់ចោទដែរ ដូចនេះសាលាឧទ្ធរណ៍ពុំចាំបាច់លើកចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារ៉ា យកមកពិចារណាទេ ។ សាលាឧទ្ធរណ៍ពិចារណា លើចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

៦-មានពិរុទ្ធភាព និងភស្តុតាង លើជនជាប់ចោទឈ្មោះ [redacted] **សេរីឧុធ** និងឈ្មោះ [redacted] **សុខណ្ណារ៉ា** ហៅ [redacted] **រ៉ា** ពីបទ លួចមានស្ថានទំងន់ទោសដោយសារប្រើអំពើហិង្សា និងបទកាន់កាប់ដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ ៥៦E០ ផ្លូវលេខ២៣០ ក្រុមទី២២ ភូមិទី៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣,៣៥៧ និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ។

៧-សាលក្រមព្រហ្មទណ្ឌលេខ ០៤ "កប៥" ចុះថ្ងៃទី ១៧.០១.២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ហើយ គ្រាន់តែសាលាឧទ្ធរណ៍ធ្វើការកែប្រែទណ្ឌកម្មខ្លះដល់ជនជាប់ចោទដែលបានសារភាព និងពិនិត្យតាមសកម្មភាព និងអំពើរបស់ជនជាប់ចោទ ប្រព្រឹត្តតាមច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ១០៣ ចុះថ្ងៃទី ០៧.០២.២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] **សេរីវុធ** និងបណ្តឹងលេខ ១៣១ ចុះថ្ងៃទី ១៨.០២.២០១៣ របស់ឈ្មោះ [redacted] **សុវណ្ណារ៉ា** ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៤ "កប៥" ចុះថ្ងៃទី ១៧.០១.២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែទណ្ឌកម្មនៅក្នុងចំណុចទី១ (ក) , (ខ) កែប្រែ ៖

**ក**-ផ្តន្ទាទោសឈ្មោះ [redacted] **សេរីវុធ** ភេទប្រុស អាយុ ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ពី០៨ឆ្នាំ (ប្រាំបីឆ្នាំ) មកដាក់ទណ្ឌកម្ម ០៥ ឆ្នាំ (ប្រាំឆ្នាំ) វិញ ។

**ខ**-ឈ្មោះ [redacted] **សុវណ្ណារ៉ា** ហៅ [redacted] **រ៉ា** ភេទប្រុស អាយុ ២៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ពី០៨ឆ្នាំ (ប្រាំបីឆ្នាំ) មកដាក់ទណ្ឌកម្ម ០៧ឆ្នាំ (ប្រាំពីរឆ្នាំ) វិញ ។

**គ**-ចំណុចផ្សេងពីនេះរក្សាទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

៤-សាលដីការនេះជំនុំជំរះនៅថ្ងៃទី ១៧.០៦.២០១៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៧.០៦.២០១៤ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

**សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះ ឱ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា: [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

ច្បាប់ចម្លងត្រឹមត្រូវតាមច្បាប់ដើម
សាលាឧទ្ធរណ៍ ថ្ងៃទី......ខែ.....១.....ឆ្នាំ២០១៤
ក្រឡាបញ្ជី
[redacted]